# ប្រកាសលេខ

# ១៣៨

# សំឡេងក្នុងទី

# កន្លែងធ្វើការ

www.ekasar.com



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ ១៣៨ ស.ក.ប.យ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៣

# ប្រកាស
# ស្តីពី
# សំឡេងក្នុងទីកន្លែងធ្វើការ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំយ៉ាងណាឱ្យប្រពលភាពសំឡេងក្នុងទីកន្លែងធ្វើការស្ថិតនៅទាបបំផុត ហើយប្រពលភាពសំឡេងនេះត្រូវស្ថិតនៅក្នុងព្រំដែនមួយដែលមិនធ្វើឱ្យខូចសុខភាពកម្មករនិយោជិត ពិសេសគឺមិនធ្វើឱ្យខូចសោតវិញ្ញាណរបស់គេទាំងពួង ។

**ប្រការ២.-** ដើម្បីទទួលបានលទ្ធផលដូចមានចែងក្នុងប្រការ១ខាងលើ និយោជកត្រូវ ៖ /.

www.ekasar.com

00193

- ឱ្យឯកសិទ្ធិទៅរបៀបផលិតណាដែលបញ្ចេញសំឡេងតិច

- បន្ថយនៅដើមប្រភពនៃប្រពលភាពសំឡេងដែលបញ្ចេញដោយបរិក្ខារការងារ ពិសេសគឺសំឡេងម៉ាស៊ីននិងគ្រឿងចក្រ

- ដាក់ឱ្យនៅដាច់ឆ្ងាយពីគេ នូវបរិក្ខារការងារណាដែលមានប្រពលភាពសំឡេងខ្លាំងនៅពេលដំណើរការ និងត្រូវការវត្តមានកម្មករនិយោជិតតិចបំផុត

- ជៀសវាងការសាយភាយសំឡេងពីរោងជាងមួយទៅរោងជាងមួយទៀត

- ចាត់ចែងការងារទៅតាមរបៀបដែលកម្មករនិយោជិតស្ថិតនៅឆ្ងាយពីប្រភពសំឡេង

- រៀបចំអគារយ៉ាងណាឱ្យសំឡេងខ្ទរត្រូវបានកាត់បន្ថយ (reverberation du bruit) ។

ប្រការ៣.- កំរិតទទួលរងសំឡេងប្រចាំថ្ងៃ ឬ កំរិតសំឡេងជាមធ្យមដែលកម្មករនិយោជិតម្នាក់ៗទទួលរងក្នុងរយៈពេលធ្វើការពេញមួយថ្ងៃ មិនត្រូវឱ្យលើសពី ៨៥ដេស៊ីបែលអា ។

ប្រការ៤.- ក្នុងករណីចាំបាច់និងនៅគ្រប់កាលៈទេសៈ ប្រសិនបើតាមលក្ខណៈបច្ចេកទេសគេមិនអាចបន្ថយប្រពលភាពសំឡេងឱ្យនៅក្រោម៨៥ដេស៊ីបែលអា បានទេ និយោជកត្រូវដាក់ឱ្យកម្មករនិយោជិតនូវបរិក្ខារការពារបុគ្គលដ៏ត្រឹមត្រូវនិងធានាថាបរិក្ខារទាំងនោះ ត្រូវបានប្រើប្រាស់ពិតប្រាកដ ។

ប្រការ៥.- ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៦. - ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- សមាគមនិយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ



1910